# អារម្ភកថា

នាពេលដែលខ្ញុំបានជួបសន្ទនាជាមួយបងប្អូនរួមជាតិយើងជាបន្តបន្ទាប់ ខ្ញុំបាននកត់សំគាល់ថា គេទាំងនោះហាក់មានចិត្តសោយឆ្ងងផុតពីទុក្ខខ្លោចផ្សារនិងកំហឹងនៃឧក្រិដ្ឋកម្ម និងការកាប់សម្លាប់ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយស្ម័គ្រចិត្តព្យាយាមវិភាគត្រិះរិះស្វែងយល់ពីព្រឹត្តិការណ៍ទាំងឡាយជុំវិញបរិបទនេះ។ ខ្ញុំមានការគោរពកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះគេទាំងនោះ។

ដើម្បីស្វែងរកការពិត, គេមិនអាចបដិសេធន៍ចោលសារៈសំខាន់នៃការវិភាគដ៏ស៊ីជម្រៅទៅលើបរិបទប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រនយោបាយដែលកើតមាននៅប្រទេសខ្មែរនារយៈពេល៣០ឆ្នាំចុងក្រោយនោះឡើយ។ គ្មានអ្វីខ្មៅងងឹតជាងប្រវត្តិសាស្ត្រ ដែលត្រូវគេពុះជៀកកម្ទេចជាបំណែកនិងការពិតក្លែងក្លាយនោះទេ។ ការណ៍ទាំងនោះបានញុំាងឲ្យមានឧក្រិដ្ឋកម្មជាហូរហែនៅក្នុងពិភពលោកទាំងមូលក្នុងនាមអ្វីដែលហៅថា "យុត្តិធម៌" នោះ។

ហេតុដូច្នេះហើយបានជា ខ្ញុំសម្រេចចិត្តសរសេរកំណត់នេះឡើង។ បងប្អូនរួបជាតិយើងអាចនឹងឃើញថា តើក្នុងអំលុងពេលជាងបីទសវត្សនេះរូបខ្ញុំត្រូវភាពចៃដន្យនៃព្យុះសង្ឃរាក្មួចបក់បោកដល់ចំណុចមួយដែលបណ្តាលឲ្យខ្ញុំក្លាយទៅជាសាក្សី ដ៏មានអភ័យឯកសិទ្ធម្នាក់នៅចំពោះមុខសង្គ្រាមដ៏សាហាវយង់ឃ្នងនិងអន្តរាយធំ ដែលបក់បោកជាបន្តបន្ទាប់ទៅលើមាតុភូមិកម្ពុជា។ នៅក្នុងចិត្តខ្ញុំ, ទោះជាយ៉ាងណា ប្រទេសខ្មែរត្រូវតែរស់រានមានជីវិតក្នុងកាលទេសៈដ៏គ្រោះថ្នាក់និងលំបាកលំបិននោះ។ មូលហេតុនេះហើយដែលខ្ញុំមិនអាចថាមិនចូលរួមបានទេ។ គ្រប់ខណៈ ដែលជាអាយុជីវិតជាតិ/នៃប្រវត្តិសាស្ត្រនាពេលនោះ ខ្ញុំបានជ្រើសរើសឈរខាងកម្លាំងណា ដែលខ្ញុំគិតថាជាកម្លាំងជាតិពិតប្រាកដទោះកេរ្តិ៍ឈ្មោះឬអំពើគេខ្លះមិនសមស្របក៏ដោយ។

ព្រឹត្តិការណ៍ដែលខ្ញុំនឹងលើកយកមកបរិយាយនាពេលនេះភាគច្រើន ច្រើនតែជាព្រឹត្តិការណ៍ដែលគេឯងធ្លាប់ដឹងឮគ្រប់ៗគ្នាហើយ។ ខ្ញុំបានពឹងផ្អែកទៅលើការស្រាវជ្រាវមួយចំនួន ដែលគេបានធ្វើរួចមកហើយដើម្បីដកស្រង់យកថ្ងៃខែមួយចំនួននិងព្រឹត្តិការណ៍ខ្លះៗដែលខ្ញុំភ្លេចអស់ទៅហើយ។ ទោះបីខ្ញុំអាចមានគំនិតខ្វែងគ្នាខ្លះនឹងអ្នកនិពន្ធទាំងឡាយ ដែលខ្ញុំនឹងលើកយកមកបកស្រាយបន្តទៅនេះ ក៏ខ្ញុំគិតថា សំនេររបស់គេសុទ្ធតែមានសារៈសំខាន់សម្រាប់ខ្ញុំទាំងអស់។

ចំពោះព្រឹត្តិការណ៍ដែលទាក់ទងនឹងអំលុងទសវត្ស ៦០-៧០ ខ្ញុំច្រើនតែផ្អែកលើសំនេររបស់លោក ហ្សូវក្រូស ជាភាសាអង់គ្លេស ក្រោមចំណងជើងថា "រឿងបន្ទាប់បន្សំ គីស៊ីងហ្គឺរ និចសុន និងការហិនហោចនៃកម្ពុជា" (ដែលត្រូវបានបកប្រែជាភាសាបារាំងដោយលោក ហ្វ្រង់ស្វ័រ-បូណេ ក្រោមចំណងជើងថា "សោកនាដ្យកម្មមួយដែលគ្មានន័យ") ។ ចំណុចអំណោយទានដ៏សំខាន់នៃសៀវភៅ

នេះ គឺអ្នកនិពន្ធបានព្យាយាមភ្ជាប់ព្រឹត្តិការណ៍និមួយៗ ដែលកើតមាននៅកម្ពុជាទៅនឹងបរិបទនៃសង្គ្រាមវៀតណាម ដើម្បីសឲ្យឃើញនូវសកម្មភាពរបស់សហរដ្ឋអាមេរិក ដែលជាគូទំនាស់មួយ, បានប្រព្រឹត្តិដើម្បីយកប្រទេសខ្មែរធ្វើជារណបសម្រាប់បំរើយុទ្ធសាស្ត្ររបស់ខ្លួន ទោះដោយស្ម័គ្រចិត្ត ឬដោយបង្ខឹត្តីៗ ខ្ញុំគិតថាការភ្ជាប់បរិបទនេះជាការត្រឹមត្រូវនិងមានអំណោយផលល្អ, មិនមែនសម្រាប់តែដើម្បីយល់ដល់អ្វីៗដែលកើតឡើងនាពេលនោះទេ តែក៏ដល់អ្វីៗដែលកើតបន្តមកទៀតដែរ។ ខ្ញុំក៏បានទាញផលចំណេញជាច្រើនពីសៀវភៅរបស់ ដាវិដ-ឆាន់ល័រ និង បិនគីណាន់ វិនគីរ៍ ជាពិសេសចំពោះព្រឹត្តិការណ៍ដែលកើតឡើងក្នុងអំលុងឆ្នាំ ១៩៧០-១៩៨០។

ប៉ុន្តែរហូតដល់ពេលនេះ មានការសិក្សាស្រាវជ្រាវតិចតួចបំផុតអំពីយុទ្ធសាស្ត្ររបស់យួនក្នុងទិសដៅផលប្រយោជន៍ជាតិគេក្នុងតំបន់។ ដើម្បីជាវិភាគទានក្នុងការស្វែងយល់ពីបុព្វហេតុនៃទំនាស់រវាងរបបកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម ខ្ញុំនឹងព្យាយាមរំពុកឡើងវិញចំពោះព្រឹត្តិការណ៍ខ្លះៗដែលខ្ញុំគិតថាមានសារៈសំខាន់ដើម្បីបំពេញចន្លោះខ្វះខាតចំពោះព្រឹត្តិការណ៍ដែលកើតឡើងនាអំលុងឆ្នាំ ១៩៧០ -១៩៧៥។

គេមិនអាចធ្វើព្រងើយកន្តើយមិនដឹងមិនឮពីបញ្ហាទាំងនោះបានទេ បើសិនជាគេចង់ដឹងចង់យល់ពីសេចក្តីមន្ទិលសង្ស័យ ពីការខកចិត្ត ពីគុំនំចំពោះគ្នាទៅវិញទៅមករវាងបក្សកុំម្មុយនិស្តកម្ពុជានិងបក្សកុំម្មុយនិស្តវៀតណាមបន្ទាប់ពីសង្គ្រាមវៀតណាមបានបញ្ចប់ទៅ ដែលបណ្តាលឲ្យក្រុមទាំងពីរត្រូវប្រឈមមុខគ្នាដោយកម្លាំងទ័ពនាអំលុងពាក់កណ្តាលឆ្នាំ១៩៧៧។

ចំពោះរយៈពេលបន្តពីពេលកើតមានវិបត្តិជាចំហររវាងភាគីទាំងពីរ ខ្ញុំបានផ្អែកលើឯកសារដែលបានរកឃើញដោយលោក ស្ទេហ្វិន-ម៉ូរីស, ដែលជាអ្នកឯកទេសបស្ចឹមប្រទេសទីមួយបានចូលទៅស្រាវជ្រាវនៅក្នុងបណ្ណដ្ឋានរបស់គណកម្មាធិការមជ្ឈឹមនៃអតីតបក្សកុំម្មុយនិស្តសូវៀត។ វាក៏ជាមូលដ្ឋានដើម្បីបញ្ជាក់កាពិតពីការយល់របស់ខ្ញុំជុំវិញបុព្វហេតុនៃវិបត្តិនេះផងដែរ។ ទិដ្ឋភាពនៃស្ថានការកម្ពុជា ដែលត្រូវទទួលគំនាបគំរាមកំហែងអធិបតេយ្យភាពដោយសម្ពាធវៀតណាមបានជះឥទ្ធិពលជាខ្លាំងទៅលើការវិវត្តន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាលើការប្រកាន់ជំហររបស់ខ្ញុំនាពេលនោះដែរ។ ដោយគិតឃើញថា កម្លាំងណាដែលតស៊ូប្រឆាំងនឹងការជ្រៀតជ្រែករបស់បរទេសដែលប្រឆាំងនឹងប្រទេសខ្ញុំៗគិតថា វាជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការឈរជាមួយរដ្ឋាភិបាលមួយដែលបេះតស៊ូការពារបូរណភាពនៃប្រទេសខ្មែរ។

គោលបំណងខ្ញុំមិនមែនចង់សរសេរសារណាអ្វីទេ ខ្ញុំគ្រាន់តែមានបំណងចង់លាតត្រដាងពីហេតុផលនៃការប្រកាន់ជុំហររបស់ខ្ញុំ។ ដោយមូលហេតុនេះហើយបានជាខ្ញុំជៀសវាងការនិយាយពីអ្នកដទៃដែលជាប់ពាក់ពិននឹងរឿងដែកគួរឲ្យឈឺចាប់នេះ លើកលែងតែចាំបាច់បំផុតក្នុងការស្វែងយល់ពីព្រឹត្តិការណ៍ដែលបានលើកយកមកបកស្រាយ។ ខ្ញុំធ្វើយ៉ាងនេះ ដើម្បីទុកឲ្យគេម្នាក់ៗពន្យល់ពីមាគ៌ា

និងហេតុផលរបស់គេម្នាក់ៗដោយខ្លួនឯងចុះ។ ទំព័របន្តទៅទៀត មិត្តអ្នកអានមួយចំនួនប្រហែលជាមានការខកចិត្តដែលពុំអាចរកឃើញនូវរឿងរ៉ាវទាំងឡាយដែលគេជញ្ជឹងគិតថា អត្ថបទនេះអាចជាពន្លឺដល់គេៗ ទោះជាយ៉ាងណាខ្ញុំគិតថា អ្វីៗដែលខ្ញុំសរសេរក្នុងអត្ថបទនេះវាគ្រប់គ្រាន់សម្រាប់ស្រាយបំភ្លឺមាគ៌ារបស់ខ្ញុំ ហើយក៏អាចជាការជួយរួមចំណែកដ៏តូចមួយក្នុងការពិចារណាលើវិនាដកម្មដ៏បង្ហូរឈាមនៅប្រទេសយើង។

ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៣
ខៀវ សំផន

## Avant-propos

A travers les entretiens que j'ai eus avec eux, j'ai pu constater que bon nombre de mes compatriotes ont su dépasser le chagrin et la révolte suscitée par les massacres et les crimes commis sous le régime du Kampuchéa Démocratique pour s'engager dans la voie de l'analyse et de la réflexion sur les événements et leur contexte. Je ne peux qu'éprouver à leur égard du respect et de l'estime.

Dans la recherche de la vérité, on ne saurait nier, en effet, l'importance d'une réflexion approfondie sur le contexte historique et géopolitique qui a prévalu au Cambodge au cours de ces trois dernières décades. Rien n'est plus nocif que l'Histoire morcelée et les fausses évidences. Elles ont déjà inspiré dans le monde bien des crimes au nom de la justice.

C'est la raison pour laquelle j'écris ces lignes. Nos compatriotes verront bien comment j'étais emporté par le hasard des tourbillons et des tempêtes pour me retrouver comme un témoin privilégié des guerres combien meurtrières et dévastatrices qui se succédèrent presque sans répit sur le territoire de notre pays au cours de presque trois décades. Cependant, puisqu'il fallait absolument, en tout cas à mes yeux, que notre pays puisse survivre à ces moments si périlleux de son histoire, je ne pouvais pas ne pas prendre parti. A chaque moment crucial de l'histoire au cours de cette période, j'ai donc choisi de me ranger au côté des forces qui, en dépit de leur renom, en dépit même, au fur et à mesure des évènements, des graves contradictions de leurs actes, me semblaient demeurer dans leur essence une force nationale.

La plupart des événements que je vais évoquer sont généralement connus et je me suis appuyé sur des recherches déjà effectuées pour en avoir les dates précises et souvent même, pour m'en remémorer un certain nombre que j'avais oubliés. Quels que puissent être mes éventuels désaccords avec les auteurs cités ci-dessous, chacun de ces textes m'a été précieux sur un point ou sur un autre.

Pour la période concernant les années soixante, soixante-dix, je me suis souvent référé à W. Shawcross dans son livre intitulé Side Show, Kissinger, Nixon and the destruction of Cambodia (ou plus exactement à sa traduction française Une tragédie sans importance, traduction de Françoise Bonnet). Le principal mérite de ce livre réside dans les efforts faits pour placer les événements survenus au Cambodge dans le contexte de la guerre du Vietnam, pour montrer comment un des belligérants, les Etats-Unis, avait déployé ses efforts pour avoir le Cambodge à son côté de gré ou de force, afin de l'utiliser au service de sa propre stratégie. Cette approche embrassant le contexte me semble rationnelle et féconde pour comprendre non seulement ce qui s'est passé pendant la guerre, mais également ce qui allait se produire après. J'ai de même tiré grand profit, en particulier pour les évènements des années 70 et 80, de mes lectures de D.P Chandler, Ben Kiernan, M. Vichery.

Par contre, peu de travaux ont étudié la stratégie vietnamienne du point de vue de ses intérêts d'État dans la sous-région. Pour apporter ma contribution à la compréhension de la genèse de la guerre entre le Kampuchéa Démocratique et le Vietnam, je me suis efforcé de me remémorer les

événements dont j'estime la connaissance essentielle pour combler les trous sur la période des années 1970-1975. On ne saurait, en effet, les ignorer, si l'on veut comprendre les suspicions, désillusions et ressentiments réciproques qui se poursuivirent entre le Parti Communiste du Kampuchéa (P.C.K.) et le Parti Communiste du Vietnam (P.C.V.) après la fin de la guerre du Vietnam, et qui conduisirent les deux partis aux confrontations militaires à partir de la deuxième moitié de l'année 1977. Pour la période qui précède immédiatement la crise ouverte dans les relations entre les deux partis, je me suis également référé aux documents découverts par Stephen J, Morris, le premier spécialiste occidental à avoir accès aux archives du Comité Central de l'ancien Parti Communiste de l'Union Soviétique, pour mettre à l'épreuve mes propres perceptions de la genèse de cette crise. Cet aspect de la situation cambodgienne, menacé dans son indépendance par la pression exercée par le Vietnam, a joué un très grand rôle à la fois sur l'évolution du régime du Kampuchéa Démocratique et sur mes propres prises de position. Considérant toutes les forces qui luttent contre l'ingérence étrangère contre mon pays comme des forces nationales, j'ai estimé de mon devoir de rester au côté du gouvernement luttant pour préserver la souveraineté du Cambodge.

Mon intention n'est pas d'écrire des mémoires, mais tout simplement d'exposer les motifs de mes prises de position. C'est la raison pour laquelle, sauf en cas de stricte nécessité pour la compréhension des événements évoqués, j'ai pris soin d'éviter de parler des autres protagonistes de cette douloureuse histoire. C'est pour laisser le soin à chacun d'expliquer son itinéraire ou ses propres motivations. Certains lecteurs seront peut-être déçus de ne pas trouver dans les pages qui suivent des anecdotes qu'ils estimeraient susceptibles d'apporter des illustrations utiles à ce texte. J'estime cependant que tel que je le livre ici, il est suffisamment clair pour éclairer mon itinéraire, et partant, peut-être, apporter une modeste contribution à la réflexion sur les drames qui ont ensanglanté notre pays

Kiev.S.P

©រក្សាសិទ្ធិគ្រប់យ៉ាង
http://www.amekhmer.org